# សុន្ទរកថា

## អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

## ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, និង ជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

## ថ្លែងក្នុង

## ពិធីបើកវេទិកាជាតិគណនេយ្យ

## ក្រោមប្រធានបទ ៖ សុខដុមនីយកម្មបទប្បញ្ញត្តិ «ការរាយការណ៍ព័ត៌មានចីរភាព និង របាយការណ៍ហិរញ្ញវត្ថុឌីជីថល»

*រាជធានីភ្នំពេញ, ថ្ងៃ ព្រហស្បតិ៍, ១២ កើត, ខែ ភទ្របទ, ឆ្នាំម្សាញ់, សប្តស័ក ព.ស. ២៥៦៩*
*ត្រូវនឹងថ្ងៃទី ៤ ខែ កញ្ញា គ.ស. ២០២៥, មជ្ឈមណ្ឌលសន្និបាត និង ពិព័រណ៍កោះពេជ្រ*

***** + *****

- *ឯកឧត្តមរដ្ឋមន្ត្រី;*
- *ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី, ភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិ, សមាជិក-សមាជិកា នៃអង្គពិធី ជាទីមេត្រី!*

ថ្ងៃនេះ, ខ្ញុំ ពិតជាមានសេចក្តីសោមនស្សក្រៃលែង ដោយបានមកចូលរួម ជាអធិបតីក្នុង វេទិកាជាតិគណនេយ្យ ក្រោមប្រធានបទ៖ **សុខដុមនីយកម្មបទប្បញ្ញត្តិ៖ «ការរាយ-ការណ៍ព័ត៌មានចីរភាព និង របាយការណ៍ហិរញ្ញវត្ថុឌីជីថល»** ។ ខ្ញុំសូមសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះ **ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី, សមាជិក-សមាជិកា នៃអង្គពិធី** ដែលបានឆ្លៀតពេលដ៏មានតម្លៃ អញ្ជើញចូលរួមក្នុងវេទិកាដ៏មានសារៈសំខាន់នេះ, ទាំងនៅទីនេះផ្ទាល់ និង ទាំងនៅពីចម្ងាយ, តាមប្រព័ន្ធអនឡាញ ។ នេះ គឺជាលើកទី ២

នៃការរៀបចំវេទិកាជាតិគណនេយ្យ, ហើយខ្ញុំនៅចាំបានថា រូបខ្ញុំ ក៏ត្រូវបានអញ្ជើញ ចូលរួមជាអធិបតី ក្នុងវេទិកាជាតិគណនេយ្យ លើកទី ១ កាលពីខែ តុលា ឆ្នាំ ២០២៤ កន្លងទៅផងដែរ; ក៏ប៉ុន្តែ, ដោយសារត្រូវជាប់បំពេញភារកិច្ចសំខាន់ផ្សេងទៀត របស់រាជរដ្ឋាភិបាល ទើបខ្ញុំមិនអាចឆ្លៀតពេលចូលរួមបាន ។

ជាការពិត, ការប្រារព្ធវេទិកាជាតិគណនេយ្យ ក្រោមប្រធានបទ ៖ **សុខដុមនីយកម្មបទប្បញ្ញត្តិ៖ «ការរាយការណ៍ព័ត៌មានចីរភាព និង របាយការណ៍ហិរញ្ញវត្ថុឌីជីថល»** នាថ្ងៃនេះ គឺជាការបង្ហាញពីឆន្ទៈមោះមុត របស់កម្ពុជា ក្នុងការលើកស្ទួយស្តង់ដាររបាយការណ៍ព័ត៌មានចីរភាព និង របាយការណ៍ហិរញ្ញវត្ថុឌីជីថល ដូចមានចែងក្នុង **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១**, ជាពិសេស **បញ្ចកោណទី ៤** ស្តីពី **ការអភិវឌ្ឍប្រកបដោយភាពធន់, ចីរភាព, និង បរិយាបន្ន**, និង **បញ្ចកោណទី ៥** ស្តីពី **ការកសាងសេដ្ឋកិច្ច និងសង្គមឌីជីថល** ។ ច្បាស់ណាស់ថា ទិវានេះ គឺជាឱកាសដ៏ពិសិដ្ឋ ក្នុងវិស័យគណនេយ្យ និងសវនកម្ម ដែលត្រូវបានរៀបចំឡើង ក្នុងគោលបំណងដើម្បីចែករំលែកនូវព័ត៌មាន ដែលត្រូវបានធ្វើបច្ចុប្បន្នភាពចុងក្រោយ ពាក់ព័ន្ធនឹងវឌ្ឍនភាពថ្មីៗ ក្នុងវិស័យគណនេយ្យ និងសវនកម្ម, ទាំងក្នុងក្របខណ្ឌជាតិ, តំបន់, និង សកលលោក, ព្រមទាំង ដើម្បីផ្តល់ឱកាសដល់អ្នកចូលរួម អាចពិភាក្សា, ផ្លាស់ប្តូរមតិយោបល់នានា, និង លើកឡើងនូវចក្ខុវិស័យជាយុទ្ធ-សាស្ត្ររួម សំដៅជំរុញចលនការនៃវិស័យគណនេយ្យ និង សវនកម្ម នៅកម្ពុជា ឲ្យមានសម្ទុះកាន់តែខ្លាំងឡើងបន្ថែមទៀត ។ លើសពីនេះទៀត, វេទិកានេះ ក៏ជាការបញ្ជាក់អំពីការ-ផ្លាស់ប្តូរជាសារវន្តនៃស្តង់ដា ក្នុងការរាយការណ៍ព័ត៌មានចីរភាព និង របាយការណ៍ហិរញ្ញវត្ថុឌីជីថល សំដៅចូលរួមលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ, រក្សាស្ថិរភាពវិស័យហិរញ្ញវត្ថុ, និងជំរុញនវានុវត្តន៍ហិរញ្ញវត្ថុ, ដែលជាគោលការណ៍ស្នូល នៃគោលនយោបាយអភិវឌ្ឍន៍បច្ចេក-វិទ្យាហិរញ្ញវត្ថុកម្ពុជា ។ ក្នុងន័យនេះ, ខ្ញុំសូមយកឱកាសដ៏ថ្លៃថ្លានេះ សម្តែងនូវការកោត-សរសើរ និង ការវាយតម្លៃខ្ពស់ ចំពោះនិយ័តករគណនេយ្យ និង សវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, ដោយមានកិច្ចសហការជិតស្និទ្ធ ពីសំណាក់ដៃគូច្រើនផ្សេងទៀត, ដែលបានសហការរៀបចំទិវាជាតិ ដ៏មានសារៈសំខាន់នេះឡើង ប្រកបដោយភាពអធិកអធមនាថ្ងៃនេះ ។

***ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី!***

ក្នុងយុគសម័យបច្ចុប្បន្ន, បច្ចេកវិទ្យាឌីជីថល បានក្លាយជាផ្នែកមួយដ៏សំខាន់ និង មិនអាចខ្វះបាន នៃការរស់នៅ, ការរៀនសូត្រ, ការប្រកបអាជីវកម្ម, ការរាយការណ៍ព័ត៌មាន និង ការផ្តល់សេវាសាធារណៈ ជូនធុរជន ក៏ដូចជា ជូនប្រជាជនទូទៅ ។ ក្នុងន័យនេះ, បច្ចេកវិទ្យាឌីជីថល បានចាក់ស្រេះក្នុងគ្រប់សកម្មភាពសង្គម-សេដ្ឋកិច្ច, ហើយបានក្លាយជាកាតាលីករដ៏សំខាន់ ក្នុងការជំរុញកំណើន និង ការពង្រឹងភាពធន់នៃសេដ្ឋកិច្ច ។ សម្រាប់វិស័យឯកជន, ការចាប់យក និង ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល, ទាំងក្នុងការ-បំពេញការងារ និង ក្នុងការរាយការណ៍ព័ត៌មាន, គឺជាឧត្តមភាពមួយថ្មី ដែលជួយលើកកម្ពស់ប្រសិទ្ធភាពការងារ, កាត់បន្ថយថ្លៃដើម, តភ្ជាប់ខ្សែច្រវាក់ផលិតកម្ម និង ធានានូវភាព-ប្រកួតប្រជែងក្នុងទីផ្សារ ។ ដូចគ្នានេះដែរ, ចំពោះវិស័យសាធារណៈ, បច្ចេកវិទ្យាឌីជីថល ក៏បាន និង កំពុង ដើរតួនាទីជាគន្លឹះដ៏សំខាន់ ក្នុងការជំរុញការកែទម្រង់នានានៅកម្ពុជា, ជាពិសេស ពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈសម្រាប់ធុរកិច្ច ដើម្បីកាត់បន្ថយភាពស្មុគ-ស្មាញនៃការិយាធិបតេយ្យ, បង្កើនប្រសិទ្ធភាពនៃរដ្ឋបាលសាធារណៈ, ពង្រឹងអនុលោមភាព និង កែលម្អបរិយាកាសធុរកិច្ចនៅកម្ពុជា ឲ្យកាន់តែប្រសើរឡើង សំដៅឆ្លើយតបទៅនឹងតម្រូវការ, សំណូមពរ និង បំណងប្រាថ្នា របស់ប្រជាជន និង ធុរជន។

ជាការពិត, ការអភិវឌ្ឍវិស័យឌីជីថល ត្រូវបានចាត់ទុកជាចលករដ៏សំខាន់មួយ ក្នុងដំណើរការអភិវឌ្ឍសេដ្ឋកិច្ច ។ រាជរដ្ឋាភិបាល សម្រាប់ នីតិកាលទី ៦ នៃរដ្ឋសភា, ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និង ភាពប្រាកដនិយម របស់ **សម្តេចអគ្គមហាសេនាបតី-តេជោ ហ៊ុន សែន**, **អតីតនាយករដ្ឋមន្ត្រី និង បច្ចុប្បន្នជា ប្រធានព្រឹទ្ធសភា**, បានប្រកាសដាក់ឲ្យអនុវត្តនូវ **«ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥»** និង **«គោលនយោបាយរដ្ឋាភិបាលឌីជីថល ២០២២-២០៣៥»**, ដែលជាឯកសារគោលនយោបាយរយៈពេលវែង សម្រាប់ធ្វើជាត្រីវិស័យ ក្នុងការរៀបចំបរិវត្តកម្មឌីជីថលរបស់កម្ពុជា ។ ការដាក់ចេញនូវឯកសារដ៏មានសារៈសំខាន់ទាំងពីរនេះ ក៏បានសបញ្ជាក់ច្បាស់ ពីឆន្ទៈមោះមុត និង ភាពបុរេសកម្ម របស់រាជរដ្ឋាភិបាល ក្នុងការប្តេជ្ញាជំរុញការអភិវឌ្ឍវិស័យឌីជីថលនៅកម្ពុជា ឲ្យកាន់តែមានភាពរស់រវើក ។

សម្រាប់ នីតិកាលទី ៧ នៃរដ្ឋសភា, ក្រោមការដឹកនាំដ៏ត្រឹមត្រូវ, ស្វាហាប់, ឈ្លាសវៃ និង ប៉ិនប្រសប់ ប្រកបដោយចក្ខុវិស័យវែងឆ្ងាយ របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**,

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា, រាជរដ្ឋាភិបាល បានដាក់ចេញនូវ **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាល ទី ១** ដើម្បី កំណើន, ការងារ, សមធម៌, ប្រសិទ្ធភាព, និង **ចីរភាព**, ដោយបានកំណត់យក **អាទិភាពគន្លឹះ ៥** រួមមាន អាទិភាពគន្លឹះ ចំនួន ៤ បន្តពី **យុទ្ធសាស្ត្រចតុកោណ** នោះគឺ៖ «**មនុស្ស, ផ្លូវ, ទឹក** និង **ភ្លើង**; និង អាទិភាព គន្លឹះបន្ថែមថ្មីមួយទៀត, ពោលគឺ **បច្ចេកវិទ្យា**, ជាពិសេស **បច្ចេកវិទ្យាឌីជីថល**, និង ដោយបន្តកំណត់យក **ការកែទម្រង់ និង ការពង្រឹងអភិបាលកិច្ច** ជា **ស្នូលនៃយុទ្ធសាស្ត្រ** ដែលផ្តោតអាទិភាព លើការធ្វើទំនើបកម្មស្ថាប័នរដ្ឋ ឲ្យក្លាយជារដ្ឋបាលសាធារណៈទំនើប ប្រកបដោយសមត្ថភាពខ្ពស់, ខ្លាំង, វៃឆ្លាត និង ស្អាតស្អំ, តាមរយៈការអនុវត្តសិទ្ធិអំណាចរដ្ឋ ខាងផ្នែកនយោបាយ, សេដ្ឋកិច្ច និង រដ្ឋបាល ក្នុងការដឹកនាំ, ការគ្រប់គ្រង និង ការចាត់ចែងកិច្ចការប្រទេស, ជាពិសេស ការធានានិរន្តរភាពនៃតួនាទី និង កិច្ចដំណើរការនៃរដ្ឋបាលសាធារណៈ ដោយយកចិត្តទុកដាក់ខ្ពស់ លើផលប្រយោជន៍ ជាតិ និង ប្រជាជន, ព្រមជាមួយនឹងការកសាងជាតិ និង ការពង្រឹងនីតិរដ្ឋ សំដៅគាំទ្រដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយបរិយាបន្ន និង ចីរភាព ។ បន្ថែមលើនេះ, ការរៀបចំនូវ **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាល ទី ១** ក៏បានឆ្លើយតបប្រកបដោយសង្គតិភាព ទៅនឹង «**ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥**» និង «**គោលនយោបាយរដ្ឋាភិបាលឌីជីថល ២០២២-២០៣៥**» ក៏ដូចជា ឆ្លើយតបទៅនឹងតម្រូវការ ក្នុងការលើកកម្ពស់ផលិតភាពសេដ្ឋកិច្ច ដែលជាគ្រឹះ និង ជាមធ្យោបាយដ៏សំខាន់ ក្នុងការសម្រេចបាន នូវ **ចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០** ។

## *ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី!*

នៅមុននេះបន្តិច, **ឯកឧត្តម ជី តាយី** រដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានគូសបញ្ជាក់ពីសម្ទុះនៃការអភិវឌ្ឍវិស័យគណនេយ្យ និង សវនកម្ម នាពេលកន្លងទៅ, ជាពិសេស បន្ទាប់ពីការរៀបចំនូវវេទិកាជាតិគណនេយ្យ ឆ្នាំ ២០២៤, ដែលជារួម, កើតចេញពីការខិតខំឥតស្រាកស្រាន្ត របស់រាជរដ្ឋាភិបាល ក្នុងការបន្តកែទម្រង់ស៊ីជម្រៅ និង មុតស្រួច និង ដោយមានការចូលរួមជិតស្និទ្ធ ពីវិស័យឯកជន សំដៅឆ្លើយតបទៅនឹងគោលដៅរួម នៃ **យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យគណនេយ្យ និង សវនកម្ម នៅកម្ពុជា ២០២៥-២០៣៥**; ពោលគឺ៖ «**កម្ពុជាមានប្រព័ន្ធគណនេយ្យ និង សវនកម្មជាតិ ដ៏រឹងមាំ, មានតម្លាភាព និង អាចជឿ**

**ទុកចិត្តបាន»** ។ ច្បាស់ណាស់ថា ក្នុងបរិការណ៍នៃការប្រែប្រួលយ៉ាងរហ័ស និង ពិបាកប៉ាន់ស្មានបាន នូវសភាពការណ៍សង្គម-សេដ្ឋកិច្ច, ទាំងក្នុងកម្រិត តំបន់ និង សកល ដូចបច្ចុប្បន្ន, យើងគ្មានជម្រើសអ្វីដែលល្អជាងការបន្តយកចិត្តទុកដាក់ ពង្រឹង និង សម្រួច កិច្ចការកែទម្រង់របស់យើង លើគ្រប់វិស័យ នោះទេ ។ ក្នុងន័យនេះ, យើងចាំបាច់ត្រូវយកចិត្តទុកដាក់ លើសុខដុម-នីយកម្មបទប្បញ្ញត្តិ ក្នុងវិស័យហិរញ្ញវត្ថុ ដើម្បីធានារក្សាស្ថិរភាពវិស័យហិរញ្ញវត្ថុ និង ជំរុញនវានុវត្តន៍ហិរញ្ញវត្ថុ ប្រកបដោយទំនុកចិត្តខ្ពស់, ខណៈសុខដុមនីយកម្មបទប្បញ្ញត្តិ ត្រូវធានាឲ្យបាន នូវគោលការណ៍ **សមភាព** ក្នុងការគ្រប់គ្រងសហគ្រាស ដើម្បីបង្កើតនូវសមាមាត្រភាព (proportionality) នៃការធ្វើបញ្ញត្តិកម្ម រវាងទំហំ និង វិស័យ របស់សហគ្រាសនីមួយៗ, ព្រមទាំង ធានានូវសង្គតិភាពជាមួយឧត្តមានុវត្តន៍អន្តរជាតិ ។

ក្នុងបរិបទនៃឌីជីថលូបនីយកម្ម, អនុលោមភាពនៃការរាយការណ៍ចីរភាព និង ការ-រាយការណ៍ហិរញ្ញវត្ថុ បានក្លាយជាអាទិភាព និង ជាមូលដ្ឋានគ្រឹះនៃការជឿទុកចិត្ត ក្នុងប្រព័ន្ធហិរញ្ញវត្ថុរបស់ជាតិ ដែលប្រមុខរាជរដ្ឋាភិបាល បានយកចិត្តទុកដាក់ ។ ជាក់ស្តែង, ក្នុងពិធីប្រកាសបើកឲ្យដំណើរការជាផ្លូវការ នូវ **សមាគមសហព័ន្ធអ្នកវិនិយោគកម្ពុជា** កាលពីថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០២៤ កន្លងទៅ, **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី** បានផ្តល់អនុសាសន៍ដ៏ខ្ពង់ខ្ពស់ ជូនវិស័យឯកជន ពាក់ព័ន្ធនឹងការពង្រឹងអនុលោមភាពជារួម ដែលទាមទារនូវការចូលរួមជិតស្និទ្ធ និង កិច្ចសហការស្អិតល្មួត ពីសំណាក់វិស័យឯកជន ។ ការពង្រឹងអនុលោមភាព, រួមបញ្ចូលនូវស្តង់ដានៃការរាយការណ៍ព័ត៌មានចីរភាព និង ព័ត៌មានហិរញ្ញវត្ថុឌីជីថល, មិនមែនត្រឹមតែជាការតម្រូវ របស់រាជរដ្ឋាភិបាលប៉ុណ្ណោះទេ, ប៉ុន្តែថែមទាំងជាការចង់បាន និង ការរំពឹងទុករបស់អតិថិជន, វិនិយោគិន និង ទីផ្សារ ផងដែរ ។ ការណ៍នេះតម្រូវឲ្យមានការផ្លាស់ប្តូរផ្នត់គំនិត ពីការយល់ឃើញថា «**អនុលោមភាព គឺជាបន្ទុក**» មកជាការទទួលស្គាល់ថា «**អនុលោមភាព គឺជាការវិនិយោគជាយុទ្ធសាស្ត្រ**» សម្រាប់សហគ្រាសគ្រប់ប្រភេទ ។

ឆ្លើយតបទៅនឹងប្រធានបទនៃវេទិការបស់យើង នាថ្ងៃនេះ, កម្ពុជា នឹងចាប់ផ្តើមអនុវត្តជាបណ្តើៗ នូវស្តង់ដានៃការរាយការណ៍ព័ត៌មានចីរភាព ផ្អែកតាមស្តង់ដានៃការរាយការណ៍ព័ត៌មានចីរភាពអន្តរជាតិ ដែលជាការអនុវត្ត ក្នុងលក្ខណៈបុរេសកម្ម ដើម្បីសម្របខ្លួនជាស្រេច ទៅតាមនិន្នាការ តំបន់ និង សកល សំដៅធានាបាននូវឧត្តមភាពប្រកួតប្រជែង ដោយ

ផ្អែកលើគោលការណ៍ដែលសមាមាត្រ តាមសមត្ថភាព, អាទិភាព និង ធនធាន របស់កម្ពុជា ។ ស្តង់ដានៃការរាយការណ៍ព័ត៌មានចីរភាពថ្មីនេះ នឹងមិនមែនគ្រាន់តែជារង្វាស់ខាងបរិស្ថានប៉ុណ្ណោះទេ, ប៉ុន្តែថែមទាំង ជាការបង្កើតតម្លៃបន្ថែម ក្នុងការទាក់ទាញការវិនិយោគពីបរទេស ដោយធានាថា ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចនៅកម្ពុជា ដំណើរការទៅមុខ ប្រកបដោយតម្លាភាព, គណនេយ្យភាព, ចីរភាព និង បរិយាបន្ន ។

## *ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី!*

លើមូលដ្ឋាននៃសាវតារួមខាងលើ, ខ្ញុំសូមយកឱកាសដ៏ថ្លៃថ្លានេះ ផ្តល់នូវអនុសាសន៍មួយចំនួន ដែលគ្រប់តួអង្គពាក់ព័ន្ធ ក្នុងវិស័យគណនេយ្យ និង សវនកម្ម, គប្បីបន្តរួមគ្នាយកចិត្តទុកដាក់ តាមសមត្ថកិច្ចរៀងខ្លួន ដូចខាងក្រោម៖

ទី១. **និយ័តករគណនេយ្យ និង សវនកម្ម** ត្រូវអនុវត្ត **យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យគណនេយ្យ និង សវនកម្ម នៅកម្ពុជា ២០២៥-២០៣៥** ប្រកបដោយស្មារតីបុរេសកម្ម, ម្ចាស់ការ និង ការទទួលខុសត្រូវខ្ពស់ ។ ខ្ញុំក៏សង្ឃឹមយ៉ាងមុតមាំថា ក្រសួង-ស្ថាប័ន និង អង្គភាពពាក់ព័ន្ធនៃរាជរដ្ឋាភិបាល ក៏ដូចជា វិស័យឯកជន នឹងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តយុទ្ធសាស្ត្រនេះ ឲ្យសម្រេចបានលទ្ធផលល្អ តាមការគ្រោងទុក ទៅតាមដំណាក់កាលនីមួយៗ ក្នុងបុព្វហេតុនៃការកសាងឲ្យបាន នូវប្រព័ន្ធគណនេយ្យ និង សវនកម្ម ដ៏រឹងមាំមួយ សម្រាប់ជាតិ ដែលអាចធានាបាននូវគណនេយ្យភាព, តម្លាភាព និង ភាពជឿទុកចិត្តបាន ។

ទី២. ក្នុងការរៀបចំស្តង់ដារបាយការណ៍ហិរញ្ញវត្ថុ, គោលនយោបាយ និង បទប្បញ្ញត្តិគណនេយ្យ និង សវនកម្ម, **និយ័តករគណនេយ្យ និង សវនកម្ម** ក៏ត្រូវបន្តធានាឲ្យបាននូវគោលការណ៍ **សមភាព** ដើម្បីបង្កើតនូវសមាមាត្រភាព (proportionality) នៃការធ្វើបញ្ញត្តិកម្ម រវាងទំហំ និង វិស័យ របស់សហគ្រាស, ព្រមទាំង ធានានូវសង្គតិភាព ជាមួយឧត្តមានុវត្តន៍អន្តរជាតិ ក្នុងការអភិវឌ្ឍវិស័យគណនេយ្យ និង សវនកម្ម ។

ទី៣. **ក្រុមហ៊ុនគណនេយ្យ និង សវនកម្ម, សហគ្រាស, អង្គការមិនស្វែងរកប្រាក់ចំណេញ, វិទ្យាស្ថានគណនេយ្យករជំនាញ និង សវនករកម្ពុជា**

**ព្រមទាំង និយ័តករគណនេយ្យ និង សវនកម្ម** ត្រូវបន្តរួមគ្នាជំរុញ និង លើកកម្ពស់កម្រិតអនុលោមភាព ក្នុងការរាយការណ៍ហិរញ្ញវត្ថុ និង ព័ត៌មានចីរភាព ដើម្បីបង្កើនទំនុកចិត្ត និង ស្ថិរភាពនៃប្រព័ន្ធហិរញ្ញវត្ថុនៅកម្ពុជា ដោយធានាថា ទីផ្សាររបស់យើង ដំណើរការប្រកបដោយប្រសិទ្ធភាព និង ស័ក្តិសិទ្ធភាព, ហើយវិនិយោគិនរបស់យើង មានទំនុកចិត្តខ្ពស់លើភាពត្រឹមត្រូវនៃទិន្នន័យហិរញ្ញវត្ថុរបស់យើង ដែលមានចីរភាព ។

**ទី៤.** **និយ័តករគណនេយ្យ និង សវនកម្ម** គួរប្រកាន់យកនូវអភិក្រម ចំនួន ៣ រួមមាន៖ ទទួលយក (adopt), បន្សាំ (adapt) និង នវានុវត្ត (innovate) ក្នុងការជំរុញបរិវត្តកម្មឌីជីថល ក្នុងសេវាកម្មគណនេយ្យ និង សវនកម្ម ។ អភិក្រមនេះ នឹងផ្តល់ឱកាសឲ្យយើង អាចរៀនសូត្រ, ដកស្រង់បទពិសោធន៍, បន្សាំខ្លួន និង បត់បែនបានល្អ ទៅនឹងសភាពការណ៍ តំបន់ និង សកល ដែលបន្តប្រែប្រួលយ៉ាងរហ័ស ដើម្បីបង្កើតជាមូលដ្ឋាន សម្រាប់ការធ្វើនវានុវត្តន៍ក្នុងវិស័យនេះ ។ និង

**ទី៥.** **និយ័តករគណនេយ្យ និង សវនកម្ម, រួមទាំងវិទ្យាស្ថានគណនេយ្យករជំនាញ និង សវនករកម្ពុជា, និង សមាគមគណនេយ្យជំនាញ ACCA** ត្រូវបន្តវិនិយោគជាយុទ្ធសាស្ត្រ លើការអភិវឌ្ឍមូលធនមនុស្ស, ជាពិសេសជំនាញវិជ្ជាជីវៈ ក្នុងការរាយការណ៍ព័ត៌មានចីរភាព និង របាយការណ៍ហិរញ្ញវត្ថុឌីជីថល ដែលត្រូវការជាចាំបាច់ ក្នុងការកសាង និង ការអភិវឌ្ឍវិស័យគណនេយ្យ និង សវនកម្ម ដើម្បីរក្សាបាននូវស្តង់ដាខ្ពស់ ។

## *ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី!*

មុននឹងបញ្ចប់, ជាថ្មីម្តងទៀត, ខ្ញុំសូមសម្តែងនូវការកោតសរសើរ ចំពោះនិយ័តករគណនេយ្យ និង សវកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, វិទ្យាស្ថានគណនេយ្យករជំនាញ និង សវនករកម្ពុជា, និង សមាគមគណនេយ្យជំនាញ ACCA ព្រមទាំងតួអង្គពាក់ព័ន្ធផ្សេងទៀត ដែលបានយកចិត្តទុកដាក់ ខិតខំលើកស្ទួយអនុលោមភាព និង ជំរុញអភិវឌ្ឍវិស័យគណនេយ្យ និង សវនកម្ម នៅកម្ពុជា ឲ្យមានការរីកចម្រើន គួរឲ្យកត់សម្គាល់ រហូតដល់បច្ចុប្បន្ន ។ ខ្ញុំសូមលើកទឹកចិត្តដល់ភាគីពាក់ព័ន្ធទាំងអស់ បន្តសកម្មចូលរួម ក្នុងការ-

លើកកម្ពស់អនុលោមភាព និង ស្តង់ដានៃការរាយការណ៍ចីរភាព និង ការរាយការណ៍ហិរញ្ញវត្ថុឌីជីថល ស្របតាមឧត្តមានុវត្តន៍អន្តរជាតិ ក្នុងស្មារតី **«រួមគិត, រួមធ្វើ និង រួមគ្នាទទួលខុសត្រូវ»** ។

ជាទីបញ្ចប់, ខ្ញុំសូមជូនពរ **ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី, ភ្ញៀវកិត្តិយស ជាតិ និង អន្តរជាតិ, សមាជិក-សមាជិកានៃអង្គពិធី** បានប្រកបដោយសុខភាពល្អបរិបូរណ៍, សម្រេចបានជោគជ័យក្នុងគ្រប់ភារកិច្ច, ព្រមទាំង ទទួលបាននូវវិបុលភាព និង សុភមង្គលក្នុងក្រុមគ្រួសាររៀងខ្លួន ។

ខ្ញុំមានកិត្តិយស សូមប្រកាសបើក **វេទិកាជាតិគណនេយ្យ ឆ្នាំ ២០២៥** **ក្រោមប្រធានបទ៖ សុខដុមនីយកម្មបទប្បញ្ញត្តិ៖ ការរាយការណ៍ព័ត៌មានចីរភាព និង របាយការណ៍ហិរញ្ញវត្ថុឌីជីថល** ចាប់ពីពេលនេះតទៅ ៕

***សូមអរគុណ !***